# រឿង ចោរលួចគោ

មាននិទានមួយថា : មានបុរសម្នាក់ទិញគោ ១ ដឹកមកដល់ផ្ទះខ្លួន ហើយរៀបចំនំចំណីចងដៃជាស្រេច រួច បុរសនោះដឹកគោចេញទៅចងឯក្រៅឲ្យឆីស្មៅ ហើយទៅដេកក្រោមម្លប់ឈើ, កំពុងតែដេកលក់ស្រួល មាន បុរសម្នាក់ដើរមកឃើញគោនោះក៏ស្រាយយកទៅ ។ បុរសម្ចាស់គោភ្ញាក់ឡើងពុំឃើញគោ ក៏ក្រោកឈរ មើលទៅឃើញចោរកំពុងដឹកគោនោះ នាំរត់ទៅ, បុរសម្ចាស់គោតាមទៅហៀបនឹងទាន់ក៏ស្រែកហៅថា “ វ៉ើ យចៅដឹកគោអញទៅណា ? ” ។ ចោរនោះមិនស្តី ។ បុរសម្ចាស់គោរត់ទៅចាប់ខ្សែគោអំពីដៃចោរ ។ ចោរថា “ យីអើ ! អញចង់អស់សំណើចនឹងចៅនេះពេកណាស់ គោអញដឹកពីផ្ទះអញមកម្ដេចក៏ចៅឯងមកចោទថា អញលួចគោចៅ ? ” ។ ចៅទាំង ២ ដណ្ដើមគោគ្នាទៅវិញទៅមក សុទ្ធតែបានរៀងៗ ខ្លួនទើបចៅទាំង ២ នោះដឹកគោទៅប្ដឹងចៅក្រមដោយដំណើរទីទៃ ៗ ពីគ្នា ។ ចៅក្រមកាត់សេចក្ដីឲ្យចៅទាំង ២ នាក់នោះពុំបាន ក៏នាំគ្នាទៅគាល់ព្រះមហាក្សត្រក្រាបបង្គំទូលតាមដំណើរនោះ ។ ឯចៅម្ចាស់គោក្រាបបង្គំទូលថា “ គោនេះ ខ្ញុំព្រះបាទអម្ចាស់ទើបនឹងទិញពីគេមកដល់ផ្ទះ ចងឲ្យទទួលព្រះរាជទានស្មៅ ខ្ញុំព្រះបាទអម្ចាស់ទៅទទួល ព្រះរាជទានដំណេកលក់ ស្រាប់តែចៅនេះមកលួចដឹកគោខ្ញុំព្រះបាទខ្ញុំព្រះបាទអម្ចាស់យកទៅ លុះខ្ញុំ ព្រះបាទអម្ចាស់ក្រោកពីដំណេកទៅតាមយកគោពីចៅនេះ ៗ ពុំព្រមឲ្យ ចេះដណ្ដើមគោពីខ្ញុំព្រះបាទអម្ចាស់ ” ។ ព្រះមហាក្សត្រទ្រង់ដណ្ដឹងថា “ គោនេះចៅឲ្យស៊ីអ្វី ? ” ។ ចៅម្ចាស់គោក្រាបទូលថា “ ឲ្យទទួលព្រះរាជ ទានស្មៅ ” ។ ចោរឆ្លើយថា “ ខ្ញុំព្រះបាទអម្ចាស់ ដឹកគោមកអំពីផ្ទះ ខ្ញុំព្រះបាទអម្ចាស់ ស្រាប់តែចៅនេះ ដើរ មកពីណា មកដណ្ដើមគោខ្ញុំ ព្រះបាទអម្ចាស់កណ្ដាលផ្លូវ ” ។ ព្រះមហាក្សត្រទ្រង់សួរថា “ គោនេះចៅឯងឲ្យ ស៊ីអ្វី ? ” ។ ចោរឆ្លើយថា “ ឲ្យទទួលព្រះរាជទានសណ្ដែក ” ។ ព្រះមហាក្សត្រឲ្យអាមាត្យយកស្លឹកប្រយង្គ បង្អកគោ ហើយគោនោះវារើចេញមក ឃើញតែស្មៅ ពុំឃើញស្លឹកសណ្ដែកដល់មួយទងនៅក្នុងពោះគោ នោះឡើយ ។ ព្រះអង្គមានព្រះបន្ទូលថា “ អានេះលួចគោមែនហើយ ” ទើបព្រះអង្គកាត់ឲ្យចៅម្ចាស់គោនោះ ឈ្នះ ។ ព្រះអង្គកាត់ដូច្នេះ ហៅសុគតិគមនំហោង ។